✓ឆ្វួតរងជាជួរជំរៅ ២-៣ សម ចន្លោះរង 0,៤ ម និង ជម្រៅ ២-៣ ស.ម។



**ការរៀបចំដីសម្រាប់ដាំដំណាំចំណីសត្វ**

**ខ.ការដាំ:** ការដាំមានពីររបៀបគឺ ដាំដោយព្រោះគ្រាប់ និង ដាំដោយបំបែកកូន។

**ការព្រោះគ្រាប់:** ត្រូវរោយគ្រាប់ពូជតាមចង្អូរជាជួររួចលប់ដីម៉្ដពីលើ។ ក្រោយពេលព្រោះបាន ២-៣ ថ្ងៃមានបើមានភ្លៀងដំណុះល្អ តែបើក្រោយពេលដាំពី ៧-១០ ថ្ងៃ គ្មានភ្លៀងត្រូវស្រោចទឹកឱ្យបានសើមល្អ។



**ការសាបកូន:** ត្រូវសាបកូននៅលើថ្នាលតូចដូចសំណាបរហូតដល់កូនស្មៅមានអាយុពី ២០-២៥ ថ្ងៃ ទើបដកទៅដាំ។ បច្ចុប្បន្នកសិករចូលចិត្តដាំដោយសាបកូន ព្រោះវាងាយស្រួលក្នុងការថែទាំ និងអាចសាបបានមុនពេលភ្លៀងធ្លាក់។

**ការថែទាំ:** ត្រូវតាមដានការលូតលាស់របស់ស្មៅ បោចស្មៅចង្រៃ ជួយដី ដាក់ជីបន្ថែមបន្ទាប់ពីដាំបាន ១៥ ថ្ងៃ និងស្រោចទឹកជាប្រចាំនៅពេលដីស្ងួត។

**ការប្រមូលផល:**

ស្មៅសីមួង អាចកាត់ឱ្យសត្វស៊ីបានលើកទី ១ នៅពេលដែលវាមានអាយុ ៩0 ថ្ងៃ និង លើកទី ២ ក្រោយពីកាត់លើកទី ១ ចំនួន ៣0-៤៥ ថ្ងៃ។ អាចលែងឱ្យសត្វស៊ីដោយខ្លួនវាក៏បាន។ កាត់ដើមកំពស់ពីផ្ទៃដីប្រមាណ ១0 ស.ម។

ស្មៅស៊ីមួង មានការដុះលូតលាស់ឡើងវិញយ៉ាងឆាប់រហ័ស បន្ទាប់ពីយើងច្រូតកាត់រួច ដូចនេះយើងត្រូវច្រូតកាត់ឱ្យបានញឹកញាប់ បើមិនដូចនេះទេវានឹងមានដើមដងរឹង និងមិនសូវមានរសជាតិចំពោះទងផ្ការបស់វា។

**ចំណាំ:** មិនគួរផ្ដល់ឱ្យសត្វស៊ីតែស្មៅមួយមុខ ត្រូវ លាយជាមួយចំបើង ឬចំណីផ្សេងទៀត ចៀសវាងការរាគរូស។


ឯកសារយោង:

គម្រោងអនុវត្តល្អប្រសើរលើការងារសុខភាព និង ផលិតកម្មគោនៅកម្ពុជា

ACIAR និង CIAT សៀវភៅបច្ចេកវិជ្ជាស្មៅដែលកំពុងអភិវឌ្ឍន៍នៅកម្ពុជា

**លន់ សុផល:** (២00៦) ដំណាំចំណីសត្វកំពុងអភិវឌ្ឍន៍ ជាមួយកសិករ



**នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល**


# ស្មៅស៊ីមួង
# Simung Grass




**រៀបចំដោយ:** ការិយាល័យផ្សព្វផ្សាយបច្ចេកទេសផលិតកម្ម និងបសុព្យាបាល នៃនាយកដ្ឋានផលិតម្ម និងបសុព្យាបាល

**អាស័យដ្ឋាន:** ផ្លូវសទ្យា ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

## ស្ថានភាពទូទៅ

ពីមុនកសិករចិញ្ចឹមសត្វជាទំលាប់ គឺលែងឱ្យស៊ីដោយសេរី។ បច្ចុប្បន្នសត្វកើន និង ផ្ទៃដីដាំដុះត្រូវបានពង្រីក នាំឱ្យដីវាលចំណីសត្វថយចុះ។ កសិករមិនអាចលែងសតដោយសេរីបានដូចមុនទៀតទេ។ កសិករភាគច្រើនត្រូវចំណាយពេលស្វែងរកចំណីសត្វ ពេលខ្លះមានការលំបាកខ្លាំងកសិករបង្ខំចិត្តកាត់បន្ថយចំនួនសត្វចិញ្ចឹម។ ដើម្បីដោះស្រាយបញ្ហានេះ **ដំណាំចំណីសត្វ គឺជាដំណោះស្រាយសាមញ្ញនិងសមស្របមួយសម្រាប់កសិករ។**

## តើដំណាំចំណីសត្វជាអ្វី ?

ដំណាំចំណិសត្វគឺជាពពួកស្មៅ ពពួកលេហ្គឹមវា និង ពពួករុក្ខជាតិលេហ្គឹម ឬ ចុល្លព្រឹកដែលគេដាំថែទាំ ស្រោចទឹក បោចស្មៅចង្រៃ សម្រាប់ប្រើប្រាស់ជាចំណីសត្វ។ ពពួកដំណាំចំណីសត្វទាំងនេះ ភាគច្រើនត្រូវបាននាំចូលមកពីបរទេសហើយដែលត្រូវបានឆ្លងកាត់ការ វាយតម្លៃដោយមានការចូលរួមពីកសិករ អ្នកផ្សព្វផ្សាយ និងអ្នកស្រាវជ្រាវដែលមានបទពិសោធន៍លើផ្នែកនេះ លើលក្ខណៈរបស់ដំណាំចំណីសត្វ ដែលសមស្របសំរាប់ដាំនៅតំបន់ត្រូពិក។ ដំណាំចំណីសត្វដែលណែនាំឱ្យកសិករដាំ គឺជាប្រភេទចំណីដែលមានការដុះលូតលាស់លឿន ទិន្នផលខ្ពស់ និង សមស្របទៅនឹងលក្ខណៈសណ្ឋានដីអាកាសធាតុប្រទេសកម្ពុជា និង សំបូរទៅដោយសារធាតុចិញ្ចឹម។

## គុណប្រយោជន៍នៃដាំណាំចំណីសត្វ

- ✓ ផ្តល់ចំណីបន្ថែមសំរាប់សត្វពេញមួយឆ្នាំ ដោះស្រាយកង្វះខាតចំណីសត្វ
- ✓ បង្កើនជីជាតិដីតាមរយៈប្រភេទដំណាំចំណីសត្វ និង ជីលាមកសត្វកើនឡើង
- ✓ ផ្តល់ដល់សត្វនូវបរិមាណ និង គុណភាពចំណី តាមក៏រិតអាហារូបត្ថម្ភ
- ✓ ដំណាំចំណីសត្វមួយចំនួន អាចជួយគ្រប់គ្រងបរិស្ថានបានល្អប្រសើរ (ជាគម្របដី ការពារដីហូរច្រោះ បង្កើនជីវជាតិដី និង បំផ្លាញស្មៅចង្រៃ)
- ✓ ចំណេញពេលវេលា និង ថវិកាចំណាយក្នុងការស្វែងរក ឬ ទិញស្មៅសំរាប់សត្វ
- ✓ ជួយកសិករ ផ្លាស់ប្តូរពីការចិញ្ចឹមសត្វបែបយថាផលមកមានការគ្រប់គ្រងល្អ។ ខាងក្រោមនេះយើងនឹងលើកយកលក្ខណៈពិសេសរបស់ស្មៅចំណីសត្វមួយប្រភេទដែលមានឈ្មោះថា ស៊ីមួង(Simung Grass)។

## ស្មៅស៊ីមួង(Simung Grass)

ពូជស្មៅស៊ីមួង មានប្រភពមកពីប្រទេសអាយវ៉ូរីខស (Ivoricost) ។ បច្ចុប្បន្ន ត្រូវបានគេនាំមកធ្វើការផ្សព្វផ្សាយ នៅតំបន់អាស៊ីអគ្នេយ៍។

ស្មៅស៊ីមួងជាពូជស្មៅដែលស្ថិតក្នុងជំពូក Panicum Maximum ជាពូជដែលមានដើមខ្ពស់ ពណ៌ស្វាយ និងស្លឹកច្រើន ស្លឹកវែងហើយទន់ ដែលសមស្របសម្រាប់ការច្រូតកាត់។ វាមានគុណភាពខ្ពស់ ដែលមានប្រូតេអ៊ីនពី ១៥-១៦% សារធាតុស្ងួតដែលអាចរលាយ បាន ៥០-៦៥% សារធាតុចិញ្ចឹម:(N=2%)។ គុណភាពស្មៅ អាចប្រែប្រួលទៅតាមទីតាំងភូមិសាស្ត្រ ដី ជីវជាតិរបស់ដី និង អាយុរបស់ស្មៅ និងត្រូវបំប៉នជីឱ្យបានញឹកញាប់។ ស្មៅនេះអាចដាំនៅហាលក្តៅ ក៏បាននៅក្នុងម្លប់បាន។ តែមិនចូលចិត្តទឹកជោគជាំពេកទេ ហើយកមិនសមស្របទៅនឹងតំបន់ដែលមានរដូវប្រាំងវែងពេកដែរ។

ទិន្នផលជាមធ្យមពី ៩៥ ទៅ ១៥០ តោន/ឆ្នាំ/ហ.ត។ ទិន្នផលពូជ ៥០ គ.ក្រ/ហិកតា។

សមស្របទាំងសម្រាប់ការច្រូតកាត់និងលែងឱ្យ សត្វស៊ី។ អាចលូតលាស់/រស់បាននៅលើដីដែលមានជីវជាតិមធ្យម តែបើដាំនៅលើដីមានជីជាតិល្អគុណភាពចំណីកាន់តែប្រសើរ។




## បច្ចេកទេសដាំ

### ក.ការរៀបចំដី

- ✓ ត្រូវជ្រើសរើសដីមិនលិចទឹក ឬ មិនជាំទឹកពេក
- ✓ ភ្ជួរដីឱ្យបានជ្រៅ ភ្ជួរពី ២-៣ ដង មុនពេលដាំ ១៤ ថ្ងៃ
- ✓ រាស់បំបែកដីឱ្យបានម៉ត់ល្អ និង ផ្ទៃដីធ្វើឱ្យបានរាបស្មើ (ងាយដាំដុះ បំប៉ន ស្រោចទឹក)
- ✓ សំអាតឫសគល់ស្មៅចង្រៃចេញឱ្យអស់